# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ អំពីប្រធានបទ លោកខៀវ-កញ្ញារិទ្ធ រដ្ឋមន្ត្រីក្រសួងពត៌មាននិយាយថា រាជរដ្ឋាភិបាលមិនអាចជួយខ្មែរកម្ពុជាក្រោមបានទេ ព្រោះខ្មែរកម្ពុជាក្រោមធ្វើអបគមន៍ទាមទារឯករាជ្យពីវៀតណាម ។

website: www.hoksavann.org

ថ្ងៃទី១៩ មិថុនា ២០០៧



ចំពោះបញ្ហានេះ យើងបាននិយាយជាញឹកញាប់មកហើយ រដ្ឋាភិបាលខ្មែរតាំងពីសម័យរដ្ឋកម្ពុជាឆ្នាំ១៩៧៩ រហូតមកដល់រដ្ឋាភិបាលចំរុះ មិនហ៊ាននិយាយនិងធ្វើអ្វីប៉ះពាល់ដល់វៀតណាមឡើយ ព្រោះអធិបតេយ្យខ្មែរពិតជាស្ថិតនៅក្រោមឥទ្ធិពលវៀតណាម ។ មិនថាតែពេលនេះទេ ដែលខ្មែរកម្ពុជាក្រោមបានទទួលទុក្ខវេទនា ហើយមិនត្រូវបានរាជរដ្ឋាភិបាលខ្មែរជួយធ្វើអន្តរាគមន៍ សូម្បីតែពេលមុនដែលសហព័ន្ធខ្មែរកម្ពុជាក្រោមមិនទាន់បានបង្កើតឡើង ក៏រដ្ឋាភិបាលខ្មែរមិនបានជួយធ្វើអន្តរាគមន៍ ជួយដោះស្រាយបញ្ហាទុក្ខវេទនារបស់ខ្មែរកម្ពុជាក្រោមដែលវៀតមធ្វើបាបដែរ ។ សូមសួរលោកខៀវ-កញ្ញារិទ្ធថា ចុះខ្មែរកម្ពុជាក្រោមនៅខេត្តមួយ ត្រូវងងិតភ្នែករាប់ពាន់នាក់នោះ តើត្រង់ហ្នឹងឬដែលថាខ្មែរកម្ពុជាក្រោមធ្វើអបគមន៍ទាមទារឯករាជ្យ ។ វៀតណាមបានបិទមិនឲ្យព្រះសង្ឃចូលរៀនពុទ្ធិកវិទ្យាល័យក្តី វៀតណាមបានរារាំងព្រះសង្ឃមិនឲ្យនិមន្តបិណ្ឌបាត្រក្តី បុណ្យកឋិនទានតាមប្រវិន័យព្រះពុទ្ធសាសនាឲ្យពុទ្ធបរិស័ទធ្វើ២៩ថ្ងៃ តែវៀតណាមកំណត់ឲ្យធ្វើតែមួយថ្ងៃទូទៅគ្រប់វត្តទាំងអស់ក្តី តើនេះឬកម្ពុជាក្រោមធ្វើអបគមន៍ទាមទារឯករាជ្យ ។ ពិសេសមួយទៀត ដីស្រែចំការរបស់ខ្មែរកម្ពុជាក្រោមជាច្រើន បានត្រូវវៀតណាមរឹបអូសយក ហើយខ្មែរកម្ពុជាក្រោមបានធ្វើបាតុកម្មប្រឆាំង តើនេះឬដែលថា ខ្មែរកម្ពុជាក្រោមធ្វើអបគមន៍ទាមទារឯករាជ្យ ។ ដូច្នេះពាក្យ

ដែលលោកខៀវ-កញ្ញារិទ្ធនិយាយថា រាជរដ្ឋាភិបាលខ្មែរមិនអាចជួយខ្មែរកម្ពុជាក្រោមបា
នទេ ព្រោះខ្មែរកម្ពុជាក្រោមធ្វើអបគមន៍ទាមទារឯករាជ្យបីវៀតណាមនោះ គ្រាន់តែជា
ពាក្យសោះជំនួសពាក្យថា ខ្ញុំជារដ្ឋាភិបាលខ្មែរមិនអាចធ្វើអ្វីបានទេ ព្រោះខ្ញុំ (រដ្ឋាភិបាល
ខ្មែរ) នៅក្រោមអំណាចវៀតណាម ។ អ្នកដឹកនាំគណបក្សប្រជាជនកម្ពុជា ភាគច្រើនទៅ
ទៀតនៅប្រទេសកុម្មុយនិស្ត មានសហភាពសូវៀត ប្រទេសវៀតណាមជាដើម ពិសេស
លោកខៀវ-កញ្ញារិទ្ធនេះ បានជិតជាប់នូវផ្នត់គំនិតកុម្មុយនិស្តវៀតណាម ។ គេនៅចាំបាន
ថា លោកខៀវ-កញ្ញារិទ្ធនេះហើយ ដែលបានរួមដៃជាមួយលោកឃុន-ហាំង ទេសរដ្ឋ
មន្ត្រីក្រសួងធម្មការនិងសាសនា កូតាហ្វ៊ុនស៊ិនប៊ិច បានចេញសរាចរមួយប្រកាសឲ្យព្រះ
សង្ឃនិងគ្រហស្ថ មុននឹងទេសនាដាក់វិទ្យុនិងទូរទស្សន៍ ត្រូវសុំច្បាប់និងមានការត្រួតពិ-
និត្យជាមុនសិន ។ នៅពេលនោះ យើងបានប្រឆាំងនឹងការរឹតត្បិតនៃការផ្សាយព្រះពុទ្ធ
សាសនានេះ ។ សរាចរនោះក៏អស់ន័យទៅ ។ ត្រង់នេះយើងសុំសួរលោកខៀវ-កញ្ញារិទ្ធ
ថា ចុះសាសនាដទៃដែលលោកខៀវ-កញ្ញារិទ្ធបានបើកឲ្យផ្សាយនោះ ហេតុដូចម្ដេចបាន
ជាមិនចេញសរាចរ ឲ្យសុំច្បាប់ហើយត្រួតពិនិត្យផង ។ ចុះវិទ្យុនិងទូរទស្សន៍ឯកជន និង
សារពត៌មានជាតិ អន្តរជាតិ ព្រឹត្តិប័ត្រនិងទស្សនាវដ្ដីផ្សាយព្រោងព្រាតនៅកម្ពុជា ហេតុ
ដូចម្ដេចមិនចេញសរាចរ ឲ្យសុំច្បាប់និងត្រួតពិនិត្យផង ។ លោកខៀវ-កញ្ញារិទ្ធមិនហ៊ាន
ចេញសរាចរត្រួតពិនិត្យ ព្រោះខ្លាចអំណាចរដ្ឋធម្មនុញ្ញត្រង់មាត្រាទី៤១ ដែលចែងថា ប្រ
ជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងពត៌មាន សេរីភា
ពខាងបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំជាដើម តែបែរជាលោកខៀវ-កញ្ញារិទ្ធរំ-
លោភលើសិទ្ធិអ្នកកាន់ព្រះពុទ្ធសាសនា ដែលជាសាសនារបស់រដ្ឋទៅវិញ ។ មិនតែប៉ុ
ណ្ណោះ លោកខៀវ-កញ្ញាបានបើកឲ្យវិទ្យុនិងទូរទស្សន៍ផ្សាយពាណិជ្ជកម្មបារី និងស្រា ជា
ថ្នាំបំពុលសម្លាប់ខ្មែរថែមទៀត ។ វិទ្យុនិងទូរទស្សន៍នៅប្រទេសប្រជាធិបតេយ្យគេផ្សាយ
មានតុល្យភាព រវាងរដ្ឋាភិបាលអ្នកកាន់អំណាចនិងបក្សប្រឆាំង ដើម្បីឲ្យប្រជាពលរដ្ឋ
បានជ្រាបនិងយកទៅពិចារណា ។ ផ្ទុយទៅវិញនៅរាជាណាចក្រកម្ពុជា លោកខៀវ-ក
ញ្ញារិទ្ធបានផ្សាយតែខាងបក្សប្រជាជនកម្ពុជា ចំណែកបក្សប្រឆាំង លោកខៀវ-កញ្ញារិទ្ធ
មិនអនុញ្ញាតឲ្យគេចាក់ផ្សាយឡើយ មានឃើញឲ្យផ្សាយការប្រជុំរដ្ឋសភា ព្រឹទ្ធសភាដែរ
កាត់ចោលមិនកើត ព្រោះមានបក្សប្រជាជនប្រជុំជាមួយ ។ វិទ្យុនិងទូរទស្សន៍ប្រទេសកុម្មុ
យនិស្ត និងប្រទេសកាន់របបផ្ដាច់ការ ហេតុដូចម្ដេចបានជាគេមិនសូវបើកស្ដាប់ ព្រោះ
ការផ្សាយជយោតែខ្លួនឯង ផ្សាយត្រង់ណាដែលល្អ កន្លែងអាក្រក់របស់ខ្លួនពុំផ្សាយឲ្យ
គេដឹងឡើយ ផ្សាយខ្លួនឯងល្អឥតខ្ចោះ ចំណែកគេវិញឃើញតែខុស ដល់គេដឹងការពិត
ថា ពួកកុម្មុយនិស្តនិងពួកផ្ដាច់ការផ្សាយភូតកុហក ពុំមែនជាអង្គការផ្សាយពត៌មានពិតទេ
ទើបគេពុំសូវបើកស្ដាប់ បើគេបើកស្ដាប់ខ្លះ ក៏ដើម្បីចង់ដឹងថា តើពួកផ្ដាច់ការនោះភូតកុ

ហាក់បែបណាខ្លះប៉ុណ្ណោះ ។ ពាក្យខ្មែរថា ពាក្យភូតចាញ់អាត្មា ។

លោកខៀវ-កញ្ញារិទ្ធជាអ្នកនាំពាក្យរាជរដ្ឋាភិបាលខ្មែរនិយាយពាក្យពុំពិត ព្រោះតុលាការវៀតណាមដែលកាត់ទោសព្រះសង្ឃខ្មែរកម្ពុជាក្រោម ដែលធ្វើបាតុកម្ម ពុំបានចោទថា ព្រះសង្ឃទាំងនោះធ្វើអបគមន៍ទាមទារឯករាជ្យ ដូចលោកខៀវ-កញ្ញារិទ្ធពោលនោះឡើយ ។ គេចោទព្រះសង្ឃទាំងនោះថា បង្កអស្ថេរភាពសង្គមនិងធ្វើឲ្យស្ទះចរាចរ ។ ដូច្នេះបញ្ជាក់ថា លោកខៀវ-កញ្ញារិទ្ធចង់ផ្គាប់ចិត្តវៀតណាមខ្លាំងពេក និយាយលើសការពិត ។ ទៅអនាគត វៀតណាមនឹងបន្តរបន្ថយការគាបសង្កត់មកលើខ្មែរកម្ពុជាក្រោម ដោយសារការតស៊ូទីរបំរះរបស់ខ្មែរកម្ពុជាក្រោម និងសម្ពាធអន្តរជាតិទៅលើវៀតណាម ។ ពេលនោះខៀវ-កញ្ញារិទ្ធ ក៏ដូចជាលោកហោង-សិរិន និងលោកខៀវ-សុភ័គ អ្នកនាំពាក្យក្រសួងមហាផ្ទៃ នឹងកែប្រែពាក្យសំដីថាតាមវៀតណាមដូចម្តេចទៀត ។ យើងសូមធ្វើសំណូមពរ សូមគណបក្សប្រជាជនកម្ពុជាព្យាយាមដកខ្លួនចេញពីឥទ្ធិពលវៀតណាម ហើយមករួបរួមជាមួយជនរួមជាតិខ្លួន ដើម្បីដោះស្រាយបញ្ហាជាតិជាមួយគ្នាក្នុងភាពឯករាជ្យ ជាពិសេសបញ្ហាដីគោកដីសមុទ្រ និងបញ្ហាអន្តោប្រវេសន៍ខុសច្បាប់ ។៚

❄ ❄

❄